# តើគោលការណ៍នឹងមានដំណើរការដូចម្ដេចដែរ?

អ្នកអប់រំនឹងប្រើប្រាស់គោលការណ៍ថ្មីនេះ នៅតាមកន្លែងមើលថែកុមារដែលមានអាយុចូលរៀនមួយចំនួន រួមមានការមើលថែគ្រួសារពេលថ្ងៃផងដែរ ដើម្បីឲ្យប្រាកដថា កូនរបស់លោកអ្នកទទួលបានបទពិសោធន៍ដែលមានគុណភាពខ្ពស់។

គោលការណ៍ផ្ដោតទៅលើសុខុមាលភាព និងការធំលូតលាស់របស់កូនលោកអ្នក។ អ្នកអប់រំនឹងធ្វើការជាមួយលោកអ្នកដើម្បីឲ្យបានស្គាល់កូនរបស់លោកអ្នក ដើម្បីឲ្យគេអាចបង្កើតកម្មវិធីមួយដែលសាងសង់លើចំណូលចិត្ត និងសមត្ថភាពរបស់កូនលោកអ្នក។ អ្នកអប់រំនឹងរក្សាផ្ដល់ព័ត៌មានដល់លោកអ្នកអំពីព្រឹត្តិការណ៍ និងសកម្មភាពទាំងឡាយដែលកូនរបស់លោកអ្នកចូលរួម។

តាមរយៈគោលដៅរៀនសូត្រចំនួន៥របស់គោលការណ៍ អ្នកអប់រំនឹងជួយកូនរបស់លោកអ្នកដើម្បីបង្កើត៖

- ឲ្យមានអារម្មណ៍យល់ដឹងយ៉ាងខ្លាំងអំពីអត្តសញ្ញាណរបស់គេ
- ការភ្ជាប់ទំនាក់ទំនងជាមួយពិភពរបស់គេ
- ឲ្យមានអារម្មណ៍យល់ដឹងយ៉ាងខ្លាំងអំពីសុខុមាលភាព
- ការជឿជាក់ក្នុងចិត្ត និងការពាក់ព័ន្ធក្នុងការរៀនសូត្ររបស់គេ
- ជំនាញផ្នែកប្រាស្រ័យទាក់ទងគ្នាដែលមានប្រសិទ្ធិភាព។

# ធ្វើការរួមគ្នា

កុមាររីកចម្រើននៅពេលដែលគ្រួសារ អ្នកអប់រំ សាលារៀន និងសហគមន៍ដ៏ធំទូលាយធ្វើការជាមួយគ្នាជាដៃគូ ដើម្បីជួយទ្រទ្រង់សុខុមាលភាព និងការរៀនសូត្ររបស់កុមារ។ ក្នុងរង្វង់ភាពជាដៃគូនេះ មនុស្សគ្រប់រូបឲ្យតម្លៃចំពោះការផ្ដល់វិភាគទានគ្នាទៅវិញទៅមក និងទាក់ទិននៅក្នុងការសម្រេចចិត្តដែលធ្វើរួមគ្នា។

ក្នុងឋានៈជាមនុស្សសំខាន់បំផុតនៅក្នុងជីវិតកូនរបស់លោកអ្នក លោកអ្នកអាចធ្វើឲ្យមានប្រយោជន៍ ដោយនិយាយជារឿយៗជាមួយអ្នកអប់រំនៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀនរបស់កូនលោកអ្នក។ ពត៌មានដែលលោកអ្នកផ្ដល់ឲ្យ អនុញ្ញាតឲ្យអ្នកអប់រំភ្ជាប់ទំនាក់ទំនងរវាងបទពិសោធន៍របស់កូនលោកអ្នកនៅផ្ទះ នៅសាលារៀន និងនៅក្នុងរង្វង់សហគមន៍ជាមួយនឹងពេលវេលា ដែលគេចំណាយជាមួយគ្នានៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន។ ការនេះជួយសម្រួលដល់ការសម្រេចចិត្តរួមគ្នាអំពីបទពិសោធន៍នៅក្នុងកន្លែងមើលថែកុមារដែលមានអាយុចូលរៀនរបស់កូនលោកអ្នក។

# អ្វីដែលកុមារបាននិយាយអំពីគំនិតសំខាន់ៗនៅក្នុងគោលការណ៍របស់កន្លែងមើលថែកុមារដែលមានអាយុចូលរៀន

*"ខ្ញុំមានអារម្មណ៍យ៉ាងពិតប្រាកដថា ខ្ញុំស្ថិតនៅក្នុងកន្លែងល្អនៅទីនេះ ពីព្រោះមានពេលវេលាសំរាប់មិត្តភក្តិ បុគ្គលិកពិតជាចេះគោរពលោកអ្នក ហើយមានអ្វីៗច្រើនទៀតសំរាប់ធ្វើ"* **Annabel អាយុ៩ឆ្នាំ**



## ស្វែងរកឲ្យដឹងច្រើនទៀត

កូនសៀវភៅតូចនេះជាការណែនាំឲ្យបានស្គាល់ **ពេលវេលារបស់ខ្ញុំ ទីកន្លែងរបស់យើង** ដែលជាគោលការណ៍សំរាប់កន្លែងមើលថែកុមារដែលមានអាយុចូលរៀននៅក្នុងប្រទេសអូស្ត្រាលី។ ដើម្បីស្វែងរកឲ្យដឹងច្រើនទៀត សូមបើកមើលវ៉ិបសាយ www.deewr.gov.au/earlychildhood ឬសួរអ្នកអប់រំមើលថែកុមារដែលមានអាយុចូលរៀនរបស់កូនលោកអ្នក។

ផលិតដោយក្រសួងអប់រំ ការងារ និងទំនាក់ទំនងនៅកន្លែងធ្វើការ សំរាប់ក្រុមប្រឹក្សារដ្ឋាភិបាលអូស្ត្រាលី នៃក្រសួងរដ្ឋាភិបាលអូស្ត្រាលី។

KHMER

# ពេលវេលារបស់ខ្ញុំ ទីកន្លែងរបស់យើង

## គោលការណ៍សំរាប់ការមើលថែកុមារដែលមានអាយុចូលរៀន នៅក្នុងប្រទេសអូស្ត្រាលី

My Time, Our Place

Framework for School Age Care in Australia





**ពត៌មានសំរាប់គ្រួសារ**

គោលការណ៍ជាតិថ្មី សំរាប់កុមារនៅកន្លែងមើលថែដែលមានអាយុចូលរៀន

## តើគោលការណ៍ថ្មីនេះអំពីអ្វី?

គោលការណ៍មានបំណងដើម្បីពង្រីក និងបង្កើនភាពខ្លឹមសារដល់សុខុមាលភាព និងការធំលូតលាស់របស់កុមារ នៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន។ គោលការណ៍ទទួលស្គាល់ថា កុមារត្រូវការកន្លែងដើម្បីទាក់ទិនក្នុងបទពិសោធន៍លើការលេង និងពេលលំហែមួយចំនួនដែលធ្វើឲ្យគេមានអារម្មណ៍សប្បាយ មានសុវត្ថិភាព និងបន្ធូរអារម្មណ៍។ គោលការណ៍ក៏ទទួលស្គាល់ផងដែរថា កុមារត្រូវការពេលដើម្បីប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាមួយជាមួយមិត្តភក្តិ ហាត់រៀនចូលរួមក្នុងសង្គម ដោះស្រាយបញ្ហា សាកល្បងសកម្មភាពថ្មីៗ និងរៀនមុខជំនាញប្រចាំជីវិត។

ការរៀនសូត្ររបស់កុមារនៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន បន្ថែមបំពេញការរៀនសូត្ររបស់គេនៅផ្ទះ និងនៅសាលារៀន។ នៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន មានសារៈសំខាន់ដ៏ធំសង្កត់ធ្ងន់ទៅលើទំនាក់ទំនង និងការបណ្តុះបណ្តាលផ្នែកទេពកោសល្យ និងចំណូលចិត្តរបស់កុមារ។



## ការលេងកំសាន្ត និងការលំហែគឺជាការរីករាយ

បទពិសោធន៍លើពេលវេលាលេងកំសាន្ត និងលំហែ ត្រូវបានជ្រើសរើសដោយកុមារ ហើយជួយទ្រទ្រង់ដោយអ្នកអប់រំដែលបានទទួលពត៌មានច្បាស់លាស់ដើម្បីលើកស្ទួយដល់ការរៀនសូត្រ និងសុខុមាលភាពរបស់កុមារ។ ភាពរីករាយសុទិដ្ឋិនិយម និងអារម្មណ៍រីករាយរបស់កុមារគឺមានសារៈសំខាន់ណាស់ដល់អារម្មណ៍ សុខុមាលភាព និងភាពរឹងប៉ឹងខាងផ្លូវចិត្តរបស់គេ។ នៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន កុមារមានការពាក់ព័ន្ធយ៉ាងសកម្មក្នុងការជ្រើសរើសសកម្មភាពផ្សេងៗ ដែលនឹងជួយពង្រីកជំនាញ និងឥរិយាបទរបស់គេសំរាប់ការរៀនសូត្រពេលមួយជីវិត។ កុមារនឹងរុករកមើលផលប្រយោជន៍រួម ហើយបង្កើតមិត្តភាព ដែលជាផ្នែកមួយរបស់សហគមន៍មើលថែកុមារដែលមានអាយុចូលរៀន។

ពេលវេលាសំរាប់ការលេងកំសាន្ត និងលំហែមានសារៈសំខាន់ជាខ្លាំងចំពោះកុមារ។ តាមរយៈសកម្មភាពលេងកំសាន្ត និងលំហែ កុមារៈ

- បង្កើតទំនាក់ទំនងជាមួយអ្នកឯទៀត
- សម្តែងឲ្យឃើញបុគ្គលិកលក្ខណៈ និងភាពតែមួយគត់របស់គេ
- បង្កើតនូវការចង់ដឹង ការឆ្នៃប្រឌិត និងជំនាញខាងការដោះស្រាយបញ្ហា
- ភ្ជាប់ទំនាក់ទំនងរវាងបទពិសោធន៍មុន និងការរៀនសូត្រពេលមួយជីវិត
- បង្កើតនូវអារម្មណ៍ដែលមានសុខុមាលភាព។

## ពេលវេលា និងទីកន្លែង

យើងបានបង្កើតគោលការណ៍ដើម្បីឲ្យប្រាកដថា កូនរបស់លោកអ្នកទទួលបានកម្មវិធីដែលមានគុណភាពនៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន។ នេះគឺជាពេលវេលា និងទីកន្លែងដ៏សំខាន់សំរាប់ឲ្យកុមារសម្រាកលំហែ បង្កើតមិត្តភក្តិ ចូលរួមក្នុងការលូតលាស់ផ្ទាល់ខ្លួន ហើយបង្កើតជំនាញ និងឥរិយាបទសំរាប់ការរស់នៅដែលមានសុខភាពល្អ។ ដោយការប្រើប្រាស់គោលការណ៍នេះ អ្នកអប់រំ (អ្នកមើលថែកូនរបស់លោកអ្នក) នឹងផ្តល់នូវបរិយាកាសដែលជាទីកន្លែងរាក់ទាក់សំរាប់កុមារ និងគ្រួសារ។ គេនឹងបង្កើតកន្លែងគួរឲ្យរំភើប និងបត់បែនដែលឆ្លើយតបទៅនឹងសុខុមាលភាព និងសមត្ថភាពនៃកុមារទាំងអស់។ ទស្សនៈនៃគោលការណ៍ គឺដើម្បីឲ្យកុមារទាំងអស់ទទួលអារម្មណ៍មានសុវត្ថិភាព និងទទួលបានបទពិសោធន៍ដែលនាំឲ្យសប្បាយរីករាយ។ ទស្សនៈនេះនឹងណែនាំអ្នកអប់រំឲ្យផ្តល់ការលេងកំសាន្ត និងពេលលំហែ យោងតាមបទពិសោធន៍ដែលគេកំពុងចូលរួម និងសាងសង់គ្រឹះសំរាប់ការរៀនសូត្រពេលមួយជីវិត។



**ពេលវេលារបស់ខ្ញុំ ទីកន្លែងរបស់យើង** ផ្តោតទៅលើការពិនិត្យមើលកុមារថាជាអ្នកចូលរួមយ៉ាងសកម្ម និងជាអ្នកធ្វើការសម្រេចចិត្ត។ កុមារនៅកន្លែងមើលថែកុមារដែលមានអាយុចូលរៀន ត្រូវបានផ្តល់ជំរើស និងការទទួលខុសត្រូវ ហើយតាមរយៈការនេះ រៀនភ្ជាប់ទំនាក់ទំនងរវាងសកម្មភាព និងផលវិបាកទាំងឡាយ។ គោលការណ៍ទទួលស្គាល់ពេលវេលា និងទីកន្លែង ក្នុងកាលកុមារសហការជាមួយអ្នកអប់រំដើម្បីរៀបចំឲ្យមានសកម្មភាព និងបទពិសោធន៍ទាំងឡាយដែលមានអត្ថន័យចំពោះគេ។ អ្នកអប់រំ និងកុមារគោរព និងទុកចិត្តគ្នាទៅវិញទៅមក ហើយរួមចំណែកដល់ការធ្វើសេចក្តីសម្រេចអំពីឱកាសនានា ដើម្បីជួយផ្គត់ផ្គង់សេចក្តីត្រូវការ និងចំណូលចិត្តរបស់កុមារ។